ព័ត៌មានសំខាន់ៗអំពីការធានារ៉ាប់រងរបស់អ្នក និងអំពើហិង្សាក្នុងគ្រួសារ

# អំពើហិង្សាក្នុងគ្រួសារ

## អ្នកមានសិទ្ធិ
## ដើម្បីមានសុវត្ថិភាព ។

## ខ្សែទូរស័ព្ទទាន់ហេតុការណ៍ដំណើរការ 24 ម៉ោង

| County<br>ខោនធី | Hotline number<br>លេខទូរស័ព្ទទាន់ហេតុការណ៍ | County<br>ខោនធី | Hotline number<br>លេខទូរស័ព្ទទាន់ហេតុការណ៍ |
|---|---|---|---|
| Adams | 800-787-8106 | Juniata | 717-242-2444 |
| Allegheny | 866-644-2882 | Lackawanna | 800-257-5765 |
| Allegheny | 888-299-4673 | Lancaster | 717-299-1249 |
| Allegheny | 866-782-0911 | Lawrence | 724-652-9036 |
| Allegheny | 412-687-8005 | Lebanon | 866-686-0451 |
| Armstrong | 724-548-8888 | Lehigh | 877-438-4957 |
| Armstrong | 800-841-8881 | Luzerne | 570-823-7312 |
| Beaver | 877-629-1841 | Luzerne | 800-424-5600 |
| Bedford | 814-623-7664 | Lycoming | 800-326-8483 |
| Bedford | 800-555-5671 | McKean | 814-368-6325 |
| Berks | 610-372-9540 | McKean | 888-822-6325 |
| Blair | 814-944-3585 | Mercer | 888-981-1457 |
| Blair | 800-500-2849 | Mercer | 724-981-1457 |
| Bradford | 570-265-5333 | Mifflin | 717-242-2444 |
| Bucks | 800-220-8116 | Monroe | 570-421-4200 |
| Butler | 800-400-8551 | Montgomery | 215-643-3150 |
| Cambria | 814-536-5361 | Montgomery | 800-642-3150 |
| Cambria | 800-999-7406 | Montgomery | 800-773-2424 |
| Cameron | 814-772-1227 | Montour | 800-544-8293 |
| Carbon | 800-424-5600 | Northampton | 877-438-4957 |
| Centre | 877-234-5050 | Northumberland | 800-850-7948 |
| Chester | 888-711-6270 | Perry | 800-852-2102 |
| Chester | 610-431-1430 | Philadelphia | 866-723-3014 |
| Clarion | 800-992-3039 | Pike | 877-296-7878 |
| Clearfield | 800-598-3998 | Potter | 877-334-3136 |
| Clinton | 570-748-9509 | Schuylkill | 570-622-6220 |
| Columbia | 800-544-8293 | Schuylkill | 800-282-0634 |
| Crawford | 814-333-9766 | Snyder | 800-850-7948 |
| Crawford | 888-881-0189 | Somerset | 800-999-7406 |
| Cumberland | 717-258-4249 | Sullivan | 800-894-3706 |
| Cumberland | 800-852-2102 | Susquehanna | 800-257-5765 |
| Dauphin | 800-654-1211 | Tioga | 800-550-0447 |
| Delaware | 610-565-4590 | Union | 800-850-7948 |
| Elk | 814-772-1227 | Venango | 800-243-4944 |
| Erie | 814-438-2675 | Warren | 814-726-1030 |
| Erie | 814-454-8161 | Warren | 800-338-3460 |
| Fayette | 800-791-4000 | Washington | 724-223-9190 |
| Forest | 800-338-3460 | Washington | 800-791-4000 |
| Franklin | 800-621-6660 | Wayne | 800-698-4847 |
| Fulton | 800-621-6660 | Westmoreland | 724-836-1122 |
| Greene | 800-791-4000 | Westmoreland | 888-832-2272 |
| Huntingdon | 814-643-1190 | Wyoming | 866-206-9050 |
| Indiana | 724-349-4444 | York | 717-846-5400 |
| Indiana | 800-435-7249 | York | 800-262-8444 |
| Jefferson | 800-598-3998 | | |

**លេខទូរស័ព្ទទាន់ហេតុការណ៍ហិង្សាក្នុងគ្រួសារថ្នាក់ជាតិ**

1-800-799-SAFE (7233) ឬ TTY 1-800-787-3224

ការហៅទូរស័ព្ទទៅលេខទូរស័ព្ទទាន់ហេតុការណ៍ថ្នាក់ជាតិ នឹងភ្ជាប់អ្នកដោយផ្ទាល់ ទៅនឹងខ្សែទូរស័ព្ទទាន់ហេតុការណ៍កម្មវិធីនៅមូលដ្ឋានរបស់អ្នក ។.

# តើអំពើហិង្សាក្នុងគ្រួសារជាអ្វី?

អំពើហិង្សាក្នុងគ្រួសារកើតឡើងនៅពេលបុគ្គលណាម្នាក់ក្នុងគ្រួសាររបស់អ្នករងគ្រោះថ្នាក់ ឬរងការគំរាមកំហែងពីសមាជិកគ្រួសារផ្សេងទៀត ។ អ្នកដែលបង្កឱ្យមានគ្រោះថ្នាក់នោះ អាចជាដៃគូ ប្តី ឬប្រពន្ធ អតីតប្តី ឬប្រពន្ធ ឬអ្នកដទៃទៀត ដែលអ្នកចាត់ទុកថាជាផ្នែកនៃគ្រួសាររបស់អ្នក ។ អំពើហិង្សាក្នុងគ្រួសារ គឺការវាយដំ ធ្វើឲ្យឈឺចាប់ ការគំរាមកំហែង ឬធ្វើឱ្យអ្នកខ្លាច ដោយតាមដានអ្នក ឬរាំងអ្នកពីការផ្លាស់ប្តូរទីកន្លែងដោយសេរី ។

## អ្នកនិងគ្រួសាររបស់អ្នកសមនឹងទទួលបានជំនួយឥតគិតថ្លៃដោយសម្ងាត់ ។

pennsylvania
DEPARTMENT OF HUMAN SERVICES

## សូមទាក់ទងទីភ្នាក់ងារផ្នែកអំពើហិង្សាក្នុងគ្រួសារនៅមូលដ្ឋានរបស់អ្នក ។

មានប្រជាពលរដ្ឋក្នុងសហគមន៍របស់អ្នក ដែលអាចជួយបាន ។ ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកដឹងថាកំពុងរស់នៅជាមួយអំពើហិង្សាក្នុងគ្រួសារ សូមទាក់ទងទីភ្នាក់ងារផ្នែកអំពើហិង្សាក្នុងគ្រួសារនៅមូលដ្ឋានរបស់អ្នក ដែលមានបញ្ជីឈ្មោះនៅក្នុងសៀវភៅនេះ ។ ទីភ្នាក់ងារផ្នែកអំពើហិង្សាក្នុងគ្រួសារផ្តល់ជូនទីជម្រក ការប្រឹក្សាយោបល់ សេវាកម្មផ្នែកច្បាប់ ការធ្វើផែនការសុវត្ថិភាព និងជំនួយផ្សេងៗទៀត ដោយឥតគិតថ្លៃ ។ អ្នកអាចទាក់ទងការិយាល័យសេវាកម្មផ្នែកច្បាប់នៅមូលដ្ឋានរបស់អ្នក ដើម្បីស្វែងយល់អំពីសិទ្ធិស្របច្បាប់របស់អ្នក ។ ទាំងអំពើហិង្សាក្នុងគ្រួសារ និងទីភ្នាក់ងារសេវាកម្មផ្នែកច្បាប់ ផ្តល់ជូនសេវាកម្មនានាដែលឥតគិតថ្លៃ និងសម្ងាត់ ។

## សូមទាក់ទងការិយាល័យសេវាកម្មប្រជាពលរដ្ឋ ឬការិយាល័យជំនួយខោនធីនៅមូលដ្ឋានរបស់អ្នក

ខណៈពេលអ្នកមិនត្រូវបានទាមទារឱ្យរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារនោះ អ្នកចង់ពិភាក្សាជាមួយបុគ្គលិកកាន់សំណុំរឿងរបស់អ្នក ដើម្បីទទួលបានជំនួយ ។ បន្ទាប់ពីបានពិភាក្សាជាមួយបុគ្គលិកកាន់សំណុំរឿងរបស់អ្នក អ្នកអាចត្រូវបានលើកលែងពីច្បាប់ស្តីពីសេវាកម្មប្រជាពលរដ្ឋថ្មីៗមួយចំនួន ប្រសិនបើការគោរពតាមច្បាប់នោះ កំណត់អ្នក ឬកូនរបស់អ្នកប្រឈមនឹងគ្រោះថ្នាក់នៃអំពើហិង្សាក្នុងគ្រួសារ ។ សូមចងចាំថា ព័ត៌មានណាមួយដែលអ្នកចែករំលែកជាមួយបុគ្គលិកកាន់សំណុំរឿងរបស់អ្នកអំពីអំពើហិង្សាក្នុងគ្រួសារនោះ គឺជាការសម្ងាត់ ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកត្រូវយល់ថា ច្បាប់កំណត់ឲ្យយើងទាំងអស់គ្នាធ្វើការរាយការណ៍អំពីការរំលោភបំពានកុមារជូនដល់ទីភ្នាក់ងារកុមារនិងយុវវ័យនៅខោនធីមូលដ្ឋានរបស់អ្នកផងដែរ ។

***ច្បាប់ស្តីពីសេវាកម្មប្រជាពលរដ្ឋខាងក្រោម អាចមិនត្រូវបានអនុវត្តចំពោះក្រុមគ្រួសារដែលកំពុងរស់នៅជាមួយអំពើហិង្សាក្នុងគ្រួសារឡើយ ។***

- ***ការងារ***
  អ្នកអាចត្រូវបានលើកលែងជាបណ្តោះអាសន្នពីការធ្វើការងារ ការស្វែងរកការងារធ្វើ ការទៅសាលារៀន ឬការចូលរួមវគ្គបណ្តុះបណ្តាលការងារ ប្រសិនបើសកម្មភាពទាំងនេះកំណត់អ្នក ឬកូនរបស់អ្នកស្ថិតក្នុងគ្រោះថ្នាក់នៃអំពើហិង្សាក្នុងគ្រួសារ ។
- ***ការគាំទ្រកុមារ***
  អ្នកអាចត្រូវបានលើកលែងពីច្បាប់ស្តីពីការគាំទ្រកុមារមួយចំនួន ប្រសិនបើមានការផ្តល់ព័ត៌មានអំពីឪពុករបស់កូនអ្នក ឬការទៅតុលាការសម្រាប់ការគាំទ្រកុមារ ធ្វើឱ្យអ្នកនិងក្រុមគ្រួសាររបស់អ្នកស្ថិតក្នុងគ្រោះថ្នាក់ ។ អ្នកអាចត្រូវបានលើកលែងពីការកំណត់អត្តសញ្ញាណឪពុករបស់កូនអ្នក ប្រសិនបើកូនរបស់អ្នកបានកើតមក ដោយសារតែអ្នកត្រូវបានគេចាប់រំលោភ ឬរំលោភបំពាន ។
- ***ឪពុកម្តាយវ័យជំទង់***
  ប្រសិនបើលោកអ្នកជាឪពុកម្តាយដែលមិនបានរៀបការ ដែលមានអាយុក្រោម 18 ឆ្នាំ អ្នកអាចមិនត្រូវបានគេទាមទារឱ្យរស់នៅជាមួយឪពុកម្តាយរបស់អ្នកឬមនុស្សពេញវ័យផ្សេងទៀតឡើយ ប្រសិនបើការរស់នៅជាមួយបុគ្គលនោះគឺមានគ្រោះថ្នាក់ដល់អ្នក ឬកូនរបស់អ្នក ។
- ***ការកំណត់ពេលវេលា***
  អ្នកអាចត្រូវបានគេលើកលែងពីការកំណត់ពេលវេលាជំនួយសាច់ប្រាក់ជាក់លាក់ ។

យើងខ្ញុំយល់ថា ការពិភាក្សាអំពីអំពើហិង្សាក្នុងគ្រួសារជារឿងផ្ទាល់ខ្លួន ។ ប្រសិនបើអ្នកចង់ប្រាប់យើងខ្ញុំអំពីការរំលោភបំពាន សូមនិយាយជាមួយបុគ្គលិកកាន់សំណុំរឿងរបស់អ្នកដោយសម្ងាត់ ។

អ្នកអាចនិយាយប្រាប់បុគ្គលិកកាន់សំណុំរឿងរបស់អ្នកអំពីអំពើហិង្សាក្នុងគ្រួសារគ្រប់ពេលវេលា ទោះបីជាអ្នកពិបាកនិយាយប្រាប់អំពីបញ្ហានេះក៏ដោយ ។ វាមានសារៈសំខាន់ណាស់ ដើម្បីទទួលបានជំនួយ ។ ទោះបីជាអ្នកនិយាយប្រាប់បុគ្គលិកកាន់សំណុំរឿងរបស់អ្នកអំពីអំពើហិង្សាក្នុងគ្រួសារនៅថ្ងៃក្រោយក៏ដោយ ក៏អ្នកនៅតែអាចទទួលបានការលើកលែងពីច្បាប់ស្តីពីសេវាកម្មប្រជាពលរដ្ឋជាក់លាក់នៅពេលនោះផងដែរ ។

**សូមហៅទូរស័ព្ទលេខ 911 ប្រសិនបើអ្នកស្ថិតនៅក្នុងគ្រោះថ្នាក់ភ្លាមៗ!**

CM 305-C 9/18